00623870

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

លេខ/No: -2-

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/០១-១០-២០១០-អវតក/អបជ(១១)**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ធុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០

---

**សាធារណៈ:**

**សាលដីកាលើសំណើរបស់ អៀង សារី ទៅអង្គបុរេជំនុំជម្រះ ហាមឃាត់អង្គជំនុំជម្រះសាលាដំបូង មិនឲ្យពិនិត្យមើលសំណុំរឿង រហូតដល់ខ្លួនមានអំណាចនឹងចាត់ការ**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY
យ៉េត ចរិយា
William SMITH

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 11 / 2010
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ជនត្រូវចោទ**
អៀង សារី

**សហមេធាវីការពារក្តី**
សុន អរុណ
Michiel PESTMAN
Victor KOPPE

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួលនូវ "សំណើរបស់ អៀង សារី ទៅអង្គបុរេជំនុំជម្រះ ហាមឃាត់អង្គជំនុំជម្រះសាលាដំបូង មិនឱ្យពិនិត្យមើលសំណុំរឿង រហូតដល់ខ្លួនមានអំណាចនឹងចាត់ការ" ("សំណើ")[១]។

## I. ប្រវត្តិនីតិវិធី

១. សហមេធាវីការពារក្ដីជនត្រូវចោទ អៀង សារី ("សហមេធាវី") បានដាក់សំណើ កាលពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១០។ មិនមានការដាក់ចម្លើយតបនោះទេ។

## II. ភាពអាចទទួលយកបាន

២. សំណើនេះស្នើសុំឱ្យអង្គបុរេជំនុំជម្រះ "ហាមឃាត់" អង្គជំនុំជម្រះសាលាដំបូងមិនឱ្យប្រើប្រាស់សិទ្ធិរបស់ខ្លួនពិនិត្យមើលសំណុំរឿង តាមវិធានផ្ទៃក្នុង ៦៩(៣) ដោយផ្អែកលើមូលដ្ឋានថា "ការត្រៀមរៀបចំជាមុន ឬដំណើរការនីតិវិធី នឹងត្រូវបានប្រឡូកប្រឡាក់ដោយចៅក្រមម្នាក់ដែលបានសារភាពថា បានទទួលសំណូក ហើយហេតុដូច្នេះជាចៅក្រមពុករលួយ"[២]។

៣. អង្គបុរេជំនុំជម្រះសូមរំឮកឡើងវិញថា ខ្លួនមិនមានយុត្តាធិការ ដើម្បីសម្រេចលើអង្គសេចក្ដីនៃពាក្យសុំរបស់សហមេធាវី ប្ដឹងជំទាស់ចៅក្រម និល ណុន ចៅក្រមនៃអង្គជំនុំជម្រះសាលដំបូងទេ[៣]។ អង្គបុរេជំនុំជម្រះក៏មិនមានយុត្តាធិការ ដើម្បីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹងបណ្ដឹងសុំប្ដឹងជំទាស់[៤] ដែលសំណើទាំងនេះត្រូវបានដាក់ជូន ហើយបានជូនដំណឹងជាឧបសម្ព័ន្ធ ក្នុង

---

[១] ថ្ងៃទី១ ខែតុលា ឆ្នាំ២០១០, ឯកសារលេខ ១ ERN 00612306-00612352 (ជាភាសាអង់គ្លេស)

[២] សំណើ, កថាខណ្ឌ ១៨

[៣] ឧបសម្ព័ន្ធ ក ឯកសារលេខ ១.២ ERN 00612337-00612352 (ជាភាសាអង់គ្លេស)

[៤] ឧបសម្ព័ន្ធ ខ ឯកសារលេខ ១.៣ ERN 00612353-00612360 (ជាភាសាអង់គ្លេស)

សំណើនេះ។ អនុលោមតាមវិធាន ៣៤(៤)(គ) ពាក្យសុំរបស់សហមេធាវីប្ដឹងជំទាស់ ត្រូវដាក់ "ប្រឆាំងនឹងចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងបញ្ហាមុនពេលជំនុំជម្រះ នៅពេលសវនាការដំបូង ឬពាក់ព័ន្ធទៅនឹងបញ្ហាកើតឡើងក្នុងអំឡុងពេលជំនុំជម្រះ ឬកាលណាភាគីមិនបានដឹងនៅមុនពេលជំនុំជម្រះ នៅមុនពេលធ្វើសេចក្ដីសម្រេចចុងក្រោយលើសំណុំរឿងនោះ"។

៤. ដោយគ្រាន់តែឧបមា តែមិនមែនជាការសម្រេចទេថា ពាក្យសុំប្ដឹងជំទាស់របស់សហមេធាវី និង/ឬ សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរបានទទួលជោគជ័យ តែសហមេធាវីមិនបានបង្ហាញដល់អង្គបុរេជំនុំជម្រះថា ការពិនិត្យមើលសំណុំរឿងមុនពេលជំនុំជម្រះរបស់ចៅក្រម និល ណុន "ក្នុងគោលបំណងត្រៀមរៀបចំជាមុនសម្រាប់ការជំនុំជម្រះ" នឹងបង្កហានិភ័យដល់ភាពយុត្តិធម៌នៃដំណើរការនីតិវិធីមុនពេលជំនុំជម្រះ និងក្នុងពេលជំនុំជម្រះឡើយ។ ដូច្នេះ អង្គបុរេជំនុំជម្រះមិនចាំបាច់សម្រេចថាតើវិធាន ២១(១) អនុញ្ញាតឲ្យខ្លួនហាមឃាត់មិនឲ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យមើលសំណុំរឿងឬអត់នោះទេ ហើយក៏មិនចាំបាច់សម្រេចថាតើវិធាន២១(១) អនុញ្ញាតឲ្យអង្គបុរេជំនុំជម្រះហាមឃាត់ក្នុងកម្រិតណានោះដែរ អនុលោមទៅតាមវិធាន៦៩(៣) នៃវិធានផ្ទៃក្នុង។

៥. សំណើនេះមិនអាចទទួលយកបានទេ។

**ផ្អែកលើសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

បដិសេធលើសំណើនេះ។

**ភ្នំពេញថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០**

**អង្គបុរេជំនុំជម្រះ**

Rowan DOWNING **ន័យ ថុល** Catherine MARCHI-UHEL **ហួត វុទ្ធី** **ប្រាក់ គីមសាន**